**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.៦១៧ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ កាត់ចេញពីដីព្រៃបម្រុងទុកអចិន្រ្តៃយ៍ និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១០០៨ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- បានឃើញលិខិតលេខ ១១៦៩ ខបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១.៦១៧ ហិកតា ក្នុងនោះ (១) ទំហំ ២០៣ ហិកតា កាត់ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ និង (២) ទំហំ ១៤៧,៥ ហិកតា កាត់ចេញពីដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង (៣) ទំហំ ១.២៦៦,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិដូចខាងក្រោម៖

- កាត់ផ្ទៃដីទំហំ ២១៣,៥ ហិកតា ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរទន្ទឹម
- កាត់ផ្ទៃដីសរុបទំហំ ៣០១,៥ ហិកតា ក្នុងនោះ (១) ទំហំ ១៥៤ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និង (២) ទំហំ ១៤៧,៥ ហិកតា កាត់ចេញពីដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតាសាញជើង
- កាត់ផ្ទៃដីសរុបទំហំ ៤៥១,៥ ហិកតា ក្នុងនោះ (១) ទំហំ ១៣០ ហិកតា កាត់ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ និង (២) ទំហំ ៣២១,៥ ហិកតា កាត់ចេញពីដី

សម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតាសាញត្បូង

- កាត់ផ្ទៃដីសរុបទំហំ ៦៥០,៥ ហិកតា ក្នុងនោះ (១) ទំហំ ៧៣ ហិកតា កាត់ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ និង (២) ទំហំ ៥៧៧,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអន្លង់ពួក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ២.០៤៥ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២.០៤៣ ក្បាលដី ជូនប្រជាពលរដ្ឋ ១.៣៣២ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីសាលារៀន) ដែលក្នុងនោះផ្តល់ជា ៖

- កម្មសិទ្ធិលើក្បាលដីសរុប ៤៨១ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៤៨០ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៤៦ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅភូមិអូរទន្ទឹម
- កម្មសិទ្ធិលើក្បាលដីឯកជន ៤៥២ ក្បាលដី ជូនប្រជាពលរដ្ឋ ៣២០ គ្រួសារ នៅភូមិតាសាញជើង
- កម្មសិទ្ធិលើក្បាលដីសរុប ៣១០ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៣០៩ ក្បាលដី ជូនប្រជាពលរដ្ឋ ២១១ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅភូមិតាសាញត្បូង
- កម្មសិទ្ធិលើក្បាលដីឯកជន ៨០២ ក្បាលដី ជូនប្រជាពលរដ្ឋ ៤៥៥ គ្រួសារ នៅភូមិអន្លង់ពួក ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបងត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការកាត់ដីទំហំ ១.៦១៧ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនយ៉ឺសាគរ កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងកាត់ចេញពីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុនគាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី




ចំនុចនីយាមការ

| ល.រ | X | Y | ល.រ | X | Y |
|---|---|---|---|---|---|
| 1 | 267983 | 1396484 | 46 | 265044 | 1392740 |
| 2 | 267912 | 1396318 | 47 | 265182 | 1392859 |
| 3 | 268050 | 1395740 | 48 | 265057 | 1393233 |
| 4 | 267723 | 1395201 | 49 | 264597 | 1393262 |
| 5 | 267810 | 1395048 | 50 | 264402 | 1393367 |
| 6 | 267547 | 1394486 | 51 | 264386 | 1393642 |
| 7 | 267813 | 1394377 | 52 | 263283 | 1394000 |
| 8 | 267524 | 1393903 | 53 | 263048 | 1393875 |
| 9 | 267194 | 1393700 | 54 | 262371 | 1393901 |
| 10 | 267444 | 1393142 | 55 | 262266 | 1394210 |
| 11 | 267733 | 1393168 | 56 | 262066 | 1394263 |
| 12 | 267707 | 1392600 | 57 | 262375 | 1395209 |
| 13 | 267043 | 1392029 | 58 | 262540 | 1395334 |
| 14 | 267008 | 1391884 | 59 | 262822 | 1395369 |
| 15 | 266910 | 1391963 | 60 | 263062 | 1395285 |
| 16 | 266805 | 1391848 | 61 | 263538 | 1395228 |
| 17 | 266707 | 1391835 | 62 | 263721 | 1395321 |
| 18 | 266534 | 1391985 | 63 | 263871 | 1395321 |
| 19 | 266112 | 1391891 | 64 | 263970 | 1395110 |
| 20 | 265866 | 1391544 | 65 | 264251 | 1395148 |
| 21 | 265673 | 1391514 | 66 | 264667 | 1394995 |
| 22 | 265444 | 1391662 | 67 | 264677 | 1394902 |
| 23 | 264875 | 1391707 | 68 | 264974 | 1394908 |
| 24 | 264761 | 1391796 | 69 | 265278 | 1394956 |
| 25 | 264553 | 1391764 | 70 | 265799 | 1394575 |
| 26 | 264337 | 1391832 | 71 | 265904 | 1394844 |
| 27 | 264296 | 1391918 | 72 | 266064 | 1394886 |
| 28 | 264180 | 1391909 | 73 | 266138 | 1394768 |
| 29 | 263825 | 1391658 | 74 | 266464 | 1394835 |
| 30 | 263672 | 1391810 | 75 | 266438 | 1395062 |
| 31 | 263542 | 1391138 | 76 | 267008 | 1395068 |
| 32 | 263606 | 1391101 | 77 | 267049 | 1395180 |
| 33 | 263533 | 1390917 | 78 | 267283 | 1395241 |
| 34 | 263410 | 1390979 | 79 | 267308 | 1395535 |
| 35 | 263334 | 1390910 | 80 | 267193 | 1395650 |
| 36 | 262934 | 1391025 | 81 | 267171 | 1395871 |
| 37 | 262899 | 1391128 | 82 | 266713 | 1395890 |
| 38 | 262426 | 1391359 | 83 | 266889 | 1396248 |
| 39 | 262489 | 1391789 | 84 | 266247 | 1396497 |
| 40 | 262778 | 1392182 | 85 | 266243 | 1397015 |
| 41 | 263154 | 1392221 | 86 | 266397 | 1397070 |
| 42 | 263670 | 1392837 | 87 | 266384 | 1396916 |
| 43 | 264166 | 1392655 | 88 | 266805 | 1396775 |
| 44 | 264221 | 1392703 | 89 | 267576 | 1396401 |
| 45 | 264629 | 1392625 | 90 | 267790 | 1396672 |

ប្រភពទិន្នន័យ: នាយកដ្ឋានភូមិសាស្ត្រ
ផែនទីព្រៃឈើ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២